# កិច្ចការបញ្ចប់មេរៀន

**អំណាន** (១០ ពិន្ទុ)

ចូរអានឧទាហរណ៍ខាងក្រោម រួចឆ្លើយនឹងសំណួរ។

> សុខាចិញ្ចឹមជ្រូកពីរក្បាល និងមាន់ ទាជាច្រើនក្បាលទៀត។ គេតែងបោសសម្អាត ទ្រុងជ្រូក មាន់ ទា ជារៀងរាល់ថ្ងៃ ដើម្បីកុំឱ្យសត្វទាំងនោះមានជំងឺ។ សុខាយកលាមកសត្វទាំងអស់នោះ ទៅចាក់ក្នុងរណ្ដៅជី ក្បែរដើមស្វាយ ឯចម្ការក្រោយផ្ទះ។ នៅពេលបោសសម្អាត សុខាតែងពាក់ម៉ាស់ការពារជានិច្ច។ ក្រោយពេលបោសសម្អាតរួច គេងូតទឹក ដុសសាប៊ូសម្អាតខ្លួនប្រាណ ដើម្បីកុំឱ្យឆ្លងមេរោគ។

គូសសញ្ញា √ ក្នុងប្រអប់ ☐ចម្លើយមួយដែលត្រឹមត្រូវជាងគេ

១. តើសុខាចិញ្ចឹមជ្រូកប៉ុន្មានក្បាល? (២ពិន្ទុ)

☐ក. ពីរក្បាល ☐ខ. បីក្បាល

☐គ. បួនក្បាល ☐ឃ. ប្រាំក្បាល

២. ដើម្បីកុំឱ្យសត្វទាំងនោះមានជំងឺ តើសុខាតែងតែធ្វើដូចម្ដេច? (២ពិន្ទុ)

☐ក. បែងចែកទៅតាមប្រភេទសត្វ ☐ខ. បោសសម្អាតទ្រុង ជារៀងរាល់ថ្ងៃ

☐គ. ចាក់ថ្នាំពេលមានជំងឺ ☐ឃ. ដាក់ចំណីឱ្យស៊ីជាប្រចាំ

៣. តើសុខាយកលាមកសត្វទាំងអស់ទៅណា? (២ពិន្ទុ)

☐ក. ឱ្យអ្នកជិតខាង ☐ខ. ចាក់ចោល

☐គ. ចាក់ក្នុងរណ្ដៅជី ឯចម្ការក្រោយផ្ទះ ☐ឃ. យកទៅលក់

៤. ពេលបោសសម្អាត ដើម្បីកុំឱ្យឆ្លងមេរោគ តើសុខាតែងធ្វើដូចម្ដេច? (២ពិន្ទុ)

☐ក. ពាក់ស្រោមជើង ☐ខ. បាញ់ថ្នាំសម្លាប់មេរោគ

☐គ. ពាក់ម៉ាស់ ☐ឃ. ពាក់អាវដៃវែង

៥. ក្រោយពេលបោសសម្អាត ដើម្បីកុំឱ្យឆ្លងមេរោគ តើសុខាតែងធ្វើដូចម្ដេច? (២ពិន្ទុ)

☐ក. ងូតទឹក ដុះសាប៊ូ ☐ខ. ចាក់ថ្នាំការពារ

☐គ. ប្ដូរខោអាវ ☐ឃ. លាងដៃ

ចូរជ្រើសរើសពាក្យនាមក្នុងប្រអប់ទៅបំពេញចន្លោះល្បះខាងក្រោម ឱ្យបានត្រឹមត្រូវ។ (៤ពិន្ទុ)

| អ្នកគ្រូ | គោក្របី | សិស្ស | ដើមឈើ | បណ្ណាល័យ |
|---|---|---|---|---|

ក.ពេលទំនេរយើងនាំគ្នាទៅអានសៀវភៅនៅឯ .............................។

ខ.យើងជា.........................ត្រូវស្ដាប់ដំបូន្មានលោកគ្រូ...................។

គ...........................ជាសត្វមានសារៈសំខាន់ចំពោះកសិករ។

ឃ............................ផ្ដល់ប្រយោជន៍ច្រើនយ៉ាងណាស់។

LIVEWORKSHEETS

ចូរគូសភ្ជាប់រូបភាពជាមួយនាមសម្គាល់ខាងក្រោមឱ្យបានត្រឹមត្រូវ។



វត្ថុ



សត្វ



រុក្ខជាតិ



ទីកន្លែង



មនុស្ស

LIVEWORKSHEETS